# រដ្ឋលេខាធិការ

សួស្តីពលរដ្ឋ Californians ជាទីមេត្រី

គ្មានសិទ្ធិអ្វីធំជាងសិទ្ធិក្នុងការបោះឆ្នោតនោះទេ។ ប្រជាធិបតេយ្យរបស់អាមេរិករីកចំរើននៅពេលដែលអ្នកមានសិទ្ធិបោះឆ្នោតគ្រប់គ្នាចូលរួម។ តាមរយៈការបោះឆ្នោត អ្នកអាចជ្រើសរើសមេដឹកនាំក្នុងតំបន់ ថ្នាក់រដ្ឋ និងថ្នាក់ជាតិរបស់អ្នក និងធានាថាសម្លេងរបស់អ្នកត្រូវបានគេស្តាប់។ ការបោះឆ្នោតបឋមដោយផ្ទាល់ទូទាំងរដ្ឋ គឺនៅថ្ងៃអង្គារទី 5 ខែមិថុនា។ ការបោះឆ្នោតកំពុងខិតជិតមកដល់ហើយ។ ខ្ញុំសូមលើកទឹកចិត្តអ្នកឱ្យចូលរួមក្នុងសិទ្ធិជាមូលដ្ឋាន គ្រឹះបំផុតរបស់អ្នកក្នុងនាមជាពលរដ្ឋនៃសហរដ្ឋអាមេរិក។

ព័ត៌មានទាំងអស់ត្រូវបានដាក់បង្ហាញនៅទីនេះជាសេចក្តីយោងសម្រាប់អ្នក។ មគ្គុទ្ទេសក៍អ្នកបោះឆ្នោតនេះអាចជួយអ្នកឱ្យធ្វើការ សម្រេចចិត្តបានត្រឹមត្រូវ។ វារួមបញ្ចូលទាំងការវិភាគមិនលំអៀង ទឡ្ហីករណ៍គាំទ្រ និងប្រឆាំងនឹងវិធានការបោះឆ្នោតជាច្រើន សេចក្តីប្រកាសរបស់បេក្ខជន កម្រងសិទ្ធិឯកកត្តជននៃអ្នកបោះឆ្នោត និងព័ត៌មានសំខាន់ៗដទៃទៀត។ មគ្គុទ្ទេសក៍នេះក៏អាចរកបានតាមអ៊ីនធឺណែតនៅលើវ៉ិបសាយរដ្ឋលេខាធិការរដ្ឋCaliforniaផងដែរ៖ *www.VoterGuide.sos.ca.gov*។

អ្នកអាចពិនិត្យមើលស្ថានភាពចុះឈ្មោះអ្នកបោះឆ្នោតគ្រប់ពេលដោយចូលមើលគេហទំព័រ *VoterStatus.sos.ca.gov*។ អ្នកអាចទាញយកកម្មវិធីបោះឆ្នោតរដ្ឋ California (VOTE CALIFORNIA) របស់យើងនៅលើស្មាតហ្វូន ឬថេប្លេតរបស់អ្នក ហើយចូលប្រើព័ត៌មាននៃការបោះឆ្នោតដ៏សំខាន់ហើយរកមើលទីតាំងបោះឆ្នោតដែលនៅជិត បំផុត។ ហើយអ្នកអាចចូលមើលគេហទំព័រ *PowerSearch.sos.ca.gov* ប្រសិនបើអ្នកចង់ដឹងបន្ថែមទៀតអំពីអ្នកដែលផ្តល់ហិរញ្ញប្បទានដល់បេក្ខជន ឬសំណើប្រជាមតិលើសន្លឹកឆ្នោត។

ប្រសិនបើអ្នកមានសំនួរអំពីរបៀបបោះឆ្នោត ឬរបៀបចុះឈ្មោះបោះឆ្នោត អ្នកអាចទាក់ទងការិយាល័យនៃរដ្ឋលេខាធិការដោយហៅទូរស័ព្ទមកលេខឥតគិតថ្លៃ (888) 345-4917។ ដើម្បីទទួលបានព័ត៌មានទំនាក់ទំនងនៃមន្រ្តីបោះឆ្នោតស្រុករបស់អ្នក សូមចូលមើលគេហទំព័ររបស់រដ្ឋលេខាធិការតាមអាសយដ្ឋាន៖ *www.sos.ca.gov/county-elections-offices*។

សូមអរគុណចំពោះការប្តេជ្ញាចិត្តរបស់អ្នកចំពោះអនាគតរបស់រដ្ឋ និងប្រទេសរបស់យើង។ ការបោះឆ្នោតបឋមដោយផ្ទាល់ទូទាំងរដ្ឋ គឺនៅថ្ងៃអង្គារទី 5 ខែមិថុនា។ សន្លឹកឆ្នោតរបស់អ្នកមានសារសំខាន់ណាស់។ សន្លឹកឆ្នោតរបស់អ្នកគឺជាសម្លេងរបស់អ្នក។ ត្រូវបានស្តាប់។ បោះឆ្នោត!